ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ២០៦៥
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣
-លេខជំនុំជម្រះ ៖ ១៣៩៧
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤
-សាលក្រមលេខ៥៦៩ (គ) ត.ព.ប្រ.ឧ
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ វេលាម៉ោង ០៨ម៉:០០នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០៦៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១០១៩ ភូមិកម្មករ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរលក់ដូរ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted]) មានកូន០២នាក់ ទោសពីមុនគ្មាន ជាទីតិជន ។

ពីបទ៖ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ</u>**

ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ និងជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ៦៣ឆ្នាំ ជាអ្នកស្គាល់រាប់អានគ្នា។ ដោយមានការជឿទុកចិត្តពីឈ្មោះ [redacted] ឈ្មោះ [redacted] តែងតែខ្ចីប្រាក់ពីឈ្មោះ [redacted] ជាច្រើនលើក ពេលខ្លះធ្វើតាមរយៈកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ពេលខ្លះពុំបានធ្វើកិច្ចសន្យានោះទេ។ លើកទី១ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឈ្មោះ [redacted] បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចំនួន $ ៦៥.០០០ (ប្រាំមុឺនប្រាំពាន់) ដុល្លាអាមេរិក លើកទី២ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២

Scanned by CamScanner

ខ្ចីប្រាក់ចំនួន $ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក លើកទី៣ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ ខ្ចីប្រាក់ចំនួន $ ៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងលើកទី៤ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៣ ខ្ចីប្រាក់ចំនួន $ ១២.១០០ (មួយម៉ឺនពីរពាន់មួយរយ)ដុល្លារអាមេរិក សរុបជាទឹកប្រាក់ទាំងអស់ចំនួន $១៧២.១០០ (ដប់ប្រាំពីរម៉ឺនពីរពាន់មួយរយ) ដុល្លារអាមេរិក។ ដល់ថ្ងៃកំណត់សងប្រាក់ឈ្មោះ[redacted]ក៏ចេញមូលប្បទានប័ត្រ របស់ធនាគារកាណាឌីយ៉ា ចំនួន០៣សន្លឹក មានលេខ ៥៥១៣១៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ,មូលប្បទានប័ត្រលេខ ៥៥១៣១៤ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $៧.៨០០ (ប្រាំពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក ,មូលប្បទានប័ត្រលេខ ៧៨១០៦៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១២.១០០ (មួយម៉ឺនពីរពាន់មួយរយ) ដុល្លារអាមេរិក និងមូលប្បទានប័ត្ររបស់ធនាគារ អេស៊ីលីដា ចំនួន០២សន្លឹក មានលេខ ១២៩៥៤៤ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១៨.០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក និងមូលប្បទានប័ត្រលេខ ១២៩៥៤៣ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក សរុបទាំងអស់មានទឹកប្រាក់ចំនួន $១៩៧.៩០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ខ្ទាត់សងមកឱ្យឈ្មោះ[redacted] លុះដល់ថ្ងៃកំណត់បើកប្រាក់ ឈ្មោះ [redacted] ក៏បានយកមូលប្បទានប័ត្រនេះទៅបើកប្រាក់ ក៏ត្រូវខាងធនាគារបញ្ជាក់ថា មូលប្បទានប័ត្រទាំង អស់ខាងលើគ្មានសាច់ប្រាក់ក្នុងគណនីទេ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៦៣ឆ្នាំ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១១៤៣ អយខ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២០១៩ ដជរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## ការពិភាក្សាដេញដោលនាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថាៈខ្លួនសូមជម្រាបជូនលោកចៅក្រមថា ដោយសារឈ្មោះ[redacted]បានខ្ចីលុយខ្លួននៅឆ្នាំ២០១២ ហើយមិនព្រមសងទេ ដោយខ្ចីលុយដប់ប្រាំពីរម៉ឺនពីរពាន់មួយរយដុល្លារអាមេរិក។ ហើយឈ្មោះនេះបានសងខ្លះ ដោយសងជាសែក តែពេលខ្លួនយកសែកទៅបើកមិនដែលមានលុយនោះទេ ហើយខ្លួនព្យាយាមទាមទាររហូត ហើយគាត់ចេញសែកសងខ្លួនទៀត តែអត់មានលុយទៀត រហូតគាត់ចេញសែកឱ្យខ្លួនចំនួនប្រាំសន្លឹក តែអត់មានលុយរហូត ទើបឈានដល់ដល់ការប្តឹងផ្តល់។ ខ្លួននិងឈ្មោះ[redacted]ជាអ្នករាប់អានគ្នាដោយខ្លួនជឿជាក់លើគាត់



Scanned by CamScanner

ព្រោះខ្លួនចូលនិវត្តន៍ហើយ ហើយសង្ឃឹមថាបានការប្រាក់ថាយ ហើយខ្លួនស្គាល់ម្តាយគាត់ ហើយខ្លួនជឿគាត់ថាគាត់មានពូនៅជប៉ុនមានផ្ទះមានដី ហើយគាត់រកស៊ីលក់គ្រឿងបន្លាស់ទើបខ្លួនហ៊ានឱ្យគាត់ខ្ចី។ ខ្លួនជាទីប្រឹក្សានៅក្រសួងការងារ។ ហើយឈ្មោះ [redacted] ជាប្តីគាត់ ហើយអ្នកចេញប័ណ្ណគឺឈ្មោះ [redacted] ទើបខ្លួនប្តឹងគាត់តែម្នាក់។ ខ្លួនមានឯកសារជាកិច្ចសន្យាខ្ចីលុយត្រឹមត្រូវ និងឯកសារបញ្ជាក់ពីធនាគារត្រឹមត្រូវ។ ចំពោះលិខិតប្រគល់ទទួលប្រាក់នៅចៅក្រមស៊ើបសួរ ឈ្មោះ [redacted] សន្យាសងបីពាន់ដុល្លារអាមេរិក តែបានធ្វើកិច្ចសន្យា តែមិនបានប្រគល់លុយឱ្យខ្លួនទេ ហើយឈ្មោះនេះសន្យាថាសងខ្លួនក្នុងមួយខែបីពាន់ដុល្លារអាមេរិក រហូតដល់សងអស់។ ឈ្ម[redacted]បានប្រគល់លុយឱ្យខ្លួនចំនួនបីពាន់ដុល្លារអាមេរិកហើយ នៅចំពោះមុខចៅក្រមស៊ើបសួរ។ ខ្លួនប្តឹងឈ្មោះ [redacted] ពីរឿងចេញសែកអត់លុយ ហើយទាមទារលុយវិញចំនួន$១៩៣.៩០០ (ដប់ប្រាំបួនម៉ឺនបីពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ហើយទាមទារជម្ងឺចិត្តចំនួន$៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ដោយខ្លួនគិតទាំងការប្រាក់ ហើយដកលុយបីពាន់ដុល្លារអាមេរិកដែលគាត់បានសងរួចហើយ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោ[redacted]នៅចៅក្រមស៊ើបសួរៈ ខ្លួនបានខ្ចីប្រាក់ពីឈ្ម[redacted]និងប្រពន្ធឈ្មោះ [redacted] ដោយមានកិច្ចសន្យាចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ មានទឹកប្រាក់ចំនួន $៦៥.០០០ (ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក , កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ មានទឹកប្រាក់ចំនួន $៥០.០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ មានទឹកប្រាក់ចំនួន $៤៥.០០០ (បួនម៉ឺនប្រាំពាន់)ដុល្លារអាមេរិក សរុបទាំងបីលើក មានចំនួន $១៦០.០០០ (ដប់ប្រាំមួយម៉ឺន)ដុល្លារអាមេរិក។ លុះដល់ថ្ងៃកំណត់សងប្រាក់ ខ្លួនពុំមានប្រាក់សងឈ្មោ[redacted]បានឱ្យខ្លួនចេញមូលប្បទានប័ត្រឱ្យគាត់លេខ៥៥១៣១៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $៦០.០០០ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក , លេខ ៥៥១៣១៤ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $៧.៨០០ (ប្រាំពីរពាន់ប្រាំបីរយ)ដុល្លារអាមេរិក , លេខ ៧៨១០៦៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១២.១០០ (មួយម៉ឺនពីរពាន់មួយរយ)ដុល្លារអាមេរិក , លេខ ១២៩៥៤៤ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១៨.០០០ (មួយម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក និងលេខ ១២៩៥៤៣ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ មានទឹកប្រាក់ចំនួន $១០០.០០០ (ដប់ម៉ឺន)ដុល្លារអាមេរិក។ ខ្លួនមិនបានជំពាក់ប្រាក់ឈ្មោ[redacted]ចំនួន$១៩៧.៩០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក នោះទេ ការពិតខ្លួនជំពាក់តែចំនួន $១៦០.០០០ (ដប់ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដូចក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។ ខ្លួនសុំសន្យាចំពោះមុខតុលាការថា ខ្លួនសងប្រាក់ទៅឈ្មោ[redacted]គ្រប់ចំនួន ដោយសន្យាសងមួយខែ $៣.០០០ (បីពាន់)ដុល្លារអាមេរិក ដោយគិតចាប់ផ្តើមសងពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៣ គឺខ្លួនយកមកប្រគល់សងឈ្មោះ[redacted]នៅតុលាការចាប់ពីថ្ងៃទី០១ ដល់ ថ្ងៃទី០៧ នៃខែនីមួយៗ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។



Scanned by CamScanner

-ក្រឡាបញ្ជីអានចម្លើយតទល់រវាងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] នៅចៅក្រមស៊ើបសួរៈ ឈ្មោះ [redacted] បានឆ្លើយថា ឈ្មោះ [redacted] ខ្ចីប្រាក់ចំនួន $១៩២.១០០ (ដប់ប្រាំបួនម៉ឺនពីរពាន់មួយរយ) ដុល្លាអាមេរិក ហើយខ្លួនគិតទាំងការប្រាក់ ឡើងដល់ចំនួន $១៩៧.៤០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លាអាមេរិក ដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។ ឯឈ្មោះ [redacted] ក៏បានទទួលស្គាល់ប្រាក់ជំពាក់ទាំងដើម ទាំងការចំនួន $១៧២.១០០ (ដប់ប្រាំពីរម៉ឺនពីរពាន់មួយរយ) ដុល្លាអាមេរិក ហើយសុំសងក្នុងមួយខែចម៉ំនួន$៣.០០០ (បីពាន់) ដុល្លាអាមេរិក រហូតរយៈពេល៦៦ខែទៅឲ្យឈ្មោះ [redacted] ឈ្មោះ [redacted] បានឆ្លើយថា ខ្លួន ឯកភាពទទួលយកសំណងក្នុងមួយខែចំនួន $៣.០០០ (បីពាន់) ដុល្លាអាមេរិក។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបន្ទាប់ពីចប់ការពិភាក្សាសួរដេញដោល**

មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា : ខ្លួនសុំឲ្យតុលាការពិនិត្យលើភស្តុតាងនៅក្នុងសំណុំរឿង ហើយចេតនារបស់ជនជាប់ចោទដោយបានចេញសែកអត់លុយឲ្យកូនក្តីខ្លួន ហើយយោងតាមចម្លើយគាត់នៅចៅក្រមស៊ើបសួរ ហើយសព្វថ្ងៃនេះជនជាប់ចោទបានផ្លាស់ប្តូរលំនៅដ្ឋានមិនដឹងរស់នៅទីណាទេ ដូចនេះគាត់មានចេតនាពិតប្រាកដក្នុងការចេញសែកអត់លុយដើម្បីឲ្យម្ចាស់បំណុលទុកចិត្ត និងដើម្បីគេចបំណុល ខ្លួនសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ : ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយរបស់ជនជាប់ចោទ និងអង្គហេតុនៅក្នុងសំណុំរឿង តំណាងអយ្យការឃើញថា៖ ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន សូមឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំឲ្យចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ ដើម្បីយកមកអនុវត្តទោសទៅតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

១) តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២០១៩ ដជរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មកជំនុំជម្រះ ពីបទៈ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញ



Scanned by CamScanner

ដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

២) ឈ្មោះ[redacted]ភេទស្រី អាយុ២៨ឆ្នាំ បានខ្ចីប្រាក់ពីឈ្មោះ[redacted]ភេទប្រុស អាយុ៦៣ ឆ្នាំ លើកទី០១ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ខ្ចីចំនួន$៦៥.០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក, លើកទី០២ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ ខ្ចីចំនួន$៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក, លើកទី០៣ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ ខ្ចីចំនួន$៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងលើកទី០៤ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៣ ខ្ចីចំនួន$១២.១០០ (មួយម៉ឺនពីរពាន់មួយរយ) ដុល្លារអាមេរិក សរុបជាទឹកប្រាក់ទាំងអស់ចំនួន$១៧២.១០០ (ដប់ប្រាំពីរម៉ឺនពីរពាន់មួយរយ) ដុល្លារអាមេរិក។ ដល់ថ្ងៃកំណត់សងប្រាក់ ឈ្មោ[redacted]ក៏ចេញមូលប្បទានប័ត្ររបស់ធនាគារកាណាឌីយ៉ា ចំនួន០៣សន្លឹក និងមូលប្បទានប័ត្ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន០២សន្លឹក សរុបទាំងអស់មានទឹកប្រាក់ចំនួន$១៩៧.៩០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ទូទាត់សងមកឱ្យឈ្មោះ[redacted]។ លុះដល់ថ្ងៃកំណត់បើកបើកប្រាក់ឈ្មោះ[redacted]ក៏បានយកមូលប្បទានប័ត្រ នេះទៅបើកប្រាក់ស្រាប់តែខាងធនាគារបញ្ជាក់ថា មូលប្បទានប័ត្រទាំងអស់ខាងលើគ្មានសាច់ប្រាក់ក្នុងគណនីទេ។ ខ្លួនសូមបញ្ជាក់ថាឈ្មោះ[redacted]ជំពាក់ប្រាក់ដើមចំនួន $១៧២,១០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក គិតជាការប្រាក់ចំនួន $២៥,៨០០ (ពីរម៉ឺនប្រាំពាន់ប្រាំបីរយ)ដុល្លារអាមេរិក សរុបទាំងដើមនិងការប្រាក់ស្មើនឹង $១៩៧,៩០០ (ដប់ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ហើយខ្លួនបានទទួលប្រាក់ចំនួន $៣,០០០ (បីពាន់) ដុល្លារអាមេរិក នៅចំពោះមុខចៅក្រមស៊ើបសួរផងដែរ។

៣) លិខិតបដិសេធមូលប្បទានប័ត្រ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងមូលប្បទានប័ត្របញ្ជូនត្រឡប់ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ បានបញ្ជាក់ថា មូលប្បទានប័ត្រនេះ សំវិធានវត្ថុគ្មាន ឬមានមិនគ្រប់គ្រាន់។

៤) ឈ្មោ[redacted]ភេទស្រី អាយុ២៨ឆ្នាំ បានដឹងថាគណនីរបស់ខ្លួន គ្មានសាច់ប្រាក់តែឈ្មោះនេះមានចេតនា ទុច្ចរិត ចេញមូលប្បទានប័ត្រ ដែលគ្មានសំវិធានវត្ថុ និងមានចេតនាធ្វើខូចប្រយោជន៍អ្នកដទៃ អំពើនេះត្រូវបានបញ្ញត្តិ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

៥) ជនជាប់ចោទឈ្មោះ[redacted]ភេទស្រី អាយុ២៨ឆ្នាំ ជាជនដែលមាន និតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណាណាមួយ ដែលធាំឱ្យមានមន្ទិលសង្ស័យ ថាជននេះមានបញ្ហាវិបល្លាសស្មារតីក្នុង ពេលប្រព្រឹត្តបទល្មើសទេ។

៦) ជនជាប់ចោទឈ្មោ[redacted]ជាជនមានការពិចារណា យល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌ នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។



Scanned by CamScanner

៧) យោងតាមអង្គហេតុ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អំណាចចម្លើយរបស់ជនជាប់ចោទ និងការប្តឹងសុំរបស់តំណាងអយ្យការនាពេលពិភាក្សាដេញដោលចំពោះមុខតុលាការយល់ឃើញថា មានពិរុទ្ធគ្រប់គ្រាន់លើជនជា ់ចោទឈ្មោះ[redacted]ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

៨) ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ាមទារប្រាក់ដើម និងការប្រាក់ចំនួន$១៩៣.៩០០ (ដប់ប្រាំបួនម៉ឺនបីពាន់ប្រាំបួនរយ) ដុល្លាអាមេរិក និងទាមទារជម្ងឺចិត្តចំនួន$៤0.000(បួនម៉ឺន) ដុល្លាអាមេរិក គប្បីតុលាការពិចារណាអំពីសំណងរដ្ឋប្បវេណី ទៅតាមច្បាប់ និងទៅតាមព្យសនកម្មជាក់ស្តែង។

**<u>ហេតុដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>សម្រេចសេចក្តី</u>**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោ[redacted]ភេទស្រី អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន **០២ ឆ្នាំ ០៦ ខែ (ពីរឆ្នាំប្រាំមួយ)** និងពិន័យជាប្រាក់កំណត់ចំនួន **៦,000,000៛** (ប្រាំមួយលានរៀល) ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ភេទស្រី អាយុ២៨ឆ្នាំ សងសំណងទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ភេទប្រុស អាយុ៦៣ឆ្នាំ ចំនួន$១៦៩.១00 (ដប់ប្រាំមួយម៉ឺនប្រាំបួនពាន់មួយរយ) ដុល្លាអាមេរិក ការទាមទារលើសពីនេះបដិសេធចោល តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]ភេទស្រី អាយុ២៨ឆ្នាំ ដើម្បីយកមកអនុវត្តទោសក្នុងពន្ធនាគារ តាមអំណាចសាលក្រមព្រហ្មទណ្ឌខាងលើ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៤ និងប្រកាសជាធារណៈនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ ទុកសិទ្ធិទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| [redacted] | **ហត្ថលេខា និងត្រា:**[redacted] |

--------------------------------------------------------------------------------

| | |
|---|---|
| | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។ |
| បានឃើញ | ភ្នំពេញ,ថ្ងៃទី[illegible] ខែតុលា ឆ្នាំ២០១៤ |
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | |



Scanned by CamScanner